ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ០០...ស.ណ.ស...សក

រាជធានីភ្នំពេញ, ថ្ងៃទី .. ខែ.. ឆ្នាំ 2009.

# សេចក្តីណែនាំ

## ស្តីពី

## ការគ្រប់គ្រងយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត

យោងអនុក្រឹត្យលេខ ១៨០ អនក្រ.បក.ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ក្រសួងសាធារណការ និងដឹកជញ្ជូន សូមធ្វើការណែនាំ ដូចខាងក្រោម :

### I- សមត្ថកិច្ចគ្រប់គ្រងយានដ្ឋាន

ក្រសួងសាធារណការ និងដឹកជញ្ជូន កំណត់បែងចែកតួនាទីភារកិច្ច និងសិទ្ធិអំណាចធ្វើការដឹកនាំ គ្រប់គ្រងលើការចុះបញ្ជី និងការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ទៅតាមទំហំ ដូចតទៅ :

១-អគ្គនាយកដ្ឋានដឹកជញ្ជូន មានតួនាទី និងភារកិច្ច ដូចខាងក្រោម:

-គ្រប់គ្រង និងរៀបចំ បែបបទ ចុះបញ្ជី ផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ដែលមានទំហំទីតាំងលើសពី ២៥០ ម៉ែត្រការ៉េឡើងទៅ

-រៀបចំសំណុំបែបបទចុះបញ្ជី ជូន ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន ពិនិត្យ និងសម្រេច

-រៀបចំបង្កើតក្រុមមន្ត្រីជំនាញ ដែលមានសមត្ថភាព និងបទពិសោធន៍ លើការងារបច្ចេកទេសយានយន្ត ធ្វើការត្រួតពិនិត្យ តាមដាន គ្រប់យានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត នៅទូទាំងប្រទេស

-ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីសុំការសម្រេច និងមានវិធានការដោះស្រាយ តាមច្បាប់ជាធរមាន។

២-មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត មានតួនាទី និងភារកិច្ច ដូចខាងក្រោម :

-គ្រប់គ្រង ចុះបញ្ជី ផ្តល់វិញ្ញាបនបត្រ និងលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត មានទំហំទីតាំងអតិបរមាត្រឹម ២៥០ ម៉ែត្រការ៉េ ដែលមានអាសយដ្ឋានស្ថិតក្នុងរាជធានី ខេត្ត របស់ខ្លួន។ ចំពោះយានដ្ឋាន ដែលមានលក្ខណៈតូចតាច ដូចជា រោងជាង ឬតូបជួសជុលទោចក្រយាន ត្រីចក្រយាន រទេះអូសដោយដៃ និងទោចក្រយានយន្ត ត្រូវស្រង់ស្ថិតិ ដើម្បីធ្វើការណែនាំ ដោយពុំចាំបាច់ចុះបញ្ជី ឬផ្តល់លិខិតអនុញ្ញាត ឡើយ

-ធ្វើរបាយការណ៍ជូនអគ្គនាយកដ្ឋានដឹកជញ្ជូន ដើម្បីចងក្រងស្ថិតិទូទាំងប្រទេស ។

## II- ការចុះបញ្ជីយានដ្ឋាន :

### ក-សំណុំឯកសារ

ជនជាតិខ្មែរ ឬជនបរទេសជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ត្រូវរៀបចំសំណុំបែបបទ សម្រាប់ដាក់ពាក្យសុំចុះបញ្ជី នៅអគ្គនាយកដ្ឋានដឹកជញ្ជូន ឬនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ហើយត្រូវមានឯកសារភ្ជាប់មកជាមួយ ដូចខាង ក្រោម :

| | |
|---|---|
| ១-ពាក្យសុំមានបិទតែមប្រៃសណីយ៍ | ១ច្បាប់ |
| ២-ប័ណ្ណគ្រួសារ ឬអត្តសញ្ញាណប័ណ្ណ | ១ច្បាប់ |
| ៣-លិខិតឆ្លងដែន នៅមានសុពលភាព ( ជនបរទេស ) | ១ច្បាប់ |
| ៤-ប្រវត្តិរូបសង្ខេបរបស់ម្ចាស់យានដ្ឋាន មានបិទរូបថត | ១ច្បាប់ |
| ៥-លិខិតថ្កោលទោស ( បញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ) | ១ច្បាប់ |
| ៦-រូបថតពណ៌ ( បីគុណនឹងបួន ) | ៣សន្លឹក |
| ៧-លក្ខន្តិកៈរបស់ក្រុមហ៊ុន ឬយានដ្ឋាន | ១ច្បាប់ |
| ៨-ប្លង់ទីតាំងយានដ្ឋាន ដែលមានការអនុញ្ញាតពីអាជ្ញាធរដែនដី | ១ច្បាប់ |
| ៩-បញ្ជីអ្នកជំនាញបច្ចេកទេស( យ៉ាងតិចមានវិស្វករ ឬអ្នកបច្ចេកទេសកម្រិតមធ្យមម្នាក់ ដែលមានបទពិសោធន៍ យ៉ាងតិច២ឆ្នាំ ) | ១ច្បាប់ |
| ១០-តារាងបរិយាយឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងយានដ្ឋាន | ១ច្បាប់ |
| ១១-នាមករណ៍យានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត | |
| ១២-ប្រភេទយានដ្ឋាន | |
| ១៣-ឯកសារផ្សេងៗទៀត ដែលចាំបាច់ ។ | |

**ខ-សំណុំឯកសារសម្រាប់សុំបើកសាខា :**

ក្នុងករណីដែលម្ចាស់យានដ្ឋានមានបំណងបើកសាខាយានដ្ឋានបន្ថែមទៀត ក្រុមហ៊ុនឬ ម្ចាស់យានដ្ឋានត្រូវដាក់ពាក្យស្នើសុំតាមបែបបទ ដូចមានចែងក្នុង ចំណុច ក ខាងលើ ។

**គ-ការសុំចុះបញ្ជីយានដ្ឋាន បន្ត :**

ចាប់ពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៩ នេះតទៅ ចំពោះក្រុមហ៊ុន ឬយានដ្ឋាន ដែលបានធ្វើការចុះបញ្ជីនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រួចហើយ ត្រូវមកធ្វើបែបបទសុំចុះបញ្ជី និងចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ឡើងវិញ ពីអគ្គនាយកដ្ឋានដឹកជញ្ជូន ឬពីមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ដោយភ្ជាប់ឯកសារមកជាមួយ ដូចមានចែងក្នុងចំណុច ក ខាងលើ និងភ្ជាប់មកជាមួយ នូវសំណុំឯកសារ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**ឃ-ការសុំប្តូរទីតាំង ផ្ទេរ ឬលក់យានដ្ឋាន :**

សំណុំបែបបទ សម្រាប់ប្តូរទីតាំង ផ្ទេរ ឬលក់យានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ម្ចាស់ក្រុមហ៊ុន ឬម្ចាស់យានដ្ឋាន ត្រូវភ្ជាប់មកជាមួយ ដូចខាងក្រោម :

១-ពាក្យសុំប្តូរទីតាំង តាមឧបសម្ព័ន្ធ ៧ ឬ១០ របស់ប្រកាសស្តីពីសំណុំបែបបទសម្រាប់ដាក់ពាក្យសុំធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត

២-ពាក្យសុំផ្ទេរ ឬលក់ តាមឧបសម្ព័ន្ធ ៨ ឬ១១ របស់ប្រកាសស្តីពីសំណុំបែបបទសម្រាប់ដាក់ពាក្យសុំធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត

៣-សំណុំបែបបទ របស់ម្ចាស់ថ្មី ដូចមានកំណត់ក្នុងចំណុច ក នៃចំណុច II ខាងលើ ។

## III- ការសុំលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋាន :

ក្រុមហ៊ុន ឬម្ចាស់យានដ្ឋាន ដែលបានមកសុំចុះបញ្ជីយានដ្ឋានរួចហើយ ត្រូវមកដាក់ពាក្យសុំធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត នៅអគ្គនាយកដ្ឋានដឹកជញ្ជូន ឬនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត។

សុពលភាពប្រើប្រាស់ នៃលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត មានរយៈពេល២ (ពីរ) ឆ្នាំ។ ក្រុមហ៊ុន ឬម្ចាស់យានដ្ឋាន ត្រូវមកដាក់ពាក្យសុំអនុញ្ញាតឱ្យធ្វើអាជីវកម្ម បន្តឡើងវិញ ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃយ៉ាងយូរបំផុត មុនអស់សុពលភាពប្រើប្រាស់។ សំណុំបែបបទសម្រាប់ដាក់ពាក្យសុំធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ត្រូវកំណត់យកដូចឧបសម្ព័ន្ធ ១ ឬ២ ឬ៤ ឬ៦ ឬ៩ ឬសម្រាប់ពាក្យសុំបន្ត ដូចឧបសម្ព័ន្ធ ៣ ឬ៥ ។

## IV- បទដ្ឋានបច្ចេកទេសក្នុងការជួសជុល និងកែច្នៃដំឡើងយានយន្ត :

**ក-ការជួសជុលយានយន្ត :**

ក្រុមហ៊ុន ឬម្ចាស់យានដ្ឋាន ត្រូវទទួលខុសត្រូវជួសជុល និងរក្សាអត្តសញ្ញាណរបស់យានយន្ត។ ក្នុងករណីមានការប្រែប្រួល ដោយប្រការណាមួយ ត្រូវដាក់ពាក្យសុំការសម្រេច ពីអគ្គនាយកដ្ឋានដឹកជញ្ជូន ឬពីមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ដើម្បីបង្កើតនូវអត្តសញ្ញាណថ្មីឡើងវិញ។ រាល់ការបង្កើតអត្តសញ្ញាណថ្មី ត្រូវមានកំណត់ហេតុទទួលខុសត្រូវពីម្ចាស់យានដ្ឋាន ជាមួយនឹងម្ចាស់យានយន្តឱ្យបានច្បាស់លាស់។ រាល់ការជួសជុលយានយន្ត ម្ចាស់

យានដ្ឋាន ត្រូវចេញវិក័យប័ត្រជូនម្ចាស់យានយន្ត និងត្រូវរក្សាទុកនូវវិក័យប័ត្រនោះ ជាឯកសារក្នុងរយៈពេល ៣ឆ្នាំ ។

**ខ-ការកែច្នៃដំឡើងយានយន្ត :**

**ខ.១-របៀបបទដាក់ពាក្យសុំកែច្នៃដំឡើងយានយន្ត :**

ក្រុមហ៊ុន ឬម្ចាស់យានដ្ឋានត្រូវដាក់ពាក្យសុំការអនុញ្ញាតកែច្នៃដំឡើងយានយន្ត នៅអគ្គនាយកដ្ឋានដឹកជញ្ជូន ឬនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយ ដូចខាងក្រោម :

| | |
|---|---|
| ១-ពាក្យសុំមានបិទតែមប្រៃសណីយ៍ | ១ច្បាប់ |
| ២-ប្រកាសស្តីពីការចុះបញ្ជីយានដ្ឋាន ថតចម្លង | ១ច្បាប់ |
| ៣-លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋាន ចាស់ ថតចម្លង | ១ច្បាប់ |
| ៤-ប្លង់កែច្នៃដំឡើងយានយន្ត | ២ច្បាប់ |
| ៥-ឯកសារផ្សេងៗទៀត ដែលចាំបាច់ ។ | |

**ខ.២-ការកែច្នៃដំឡើងយានយន្ត :**

ក្រុមហ៊ុន ឬម្ចាស់យានដ្ឋាន ត្រូវទទួលខុសត្រូវ លើការកែច្នៃដំឡើងយានយន្ត ឱ្យបានត្រឹមត្រូវតាមលក្ខណបច្ចេកទេស ដែលមានដូចខាងក្រោម:

-មុននឹងធ្វើការកែច្នៃដំឡើងយានយន្ត ត្រូវមានគម្រោងប្លង់បច្ចេកទេស និងមានការចុះហត្ថលេខាទទួលខុសត្រូវ ពីក្រុមអ្នកបច្ចេកទេស និងម្ចាស់យានដ្ឋាន ដើម្បីដាក់ជូនអគ្គនាយកដ្ឋានដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ពិនិត្យសម្រេច

-ការកែច្នៃដំឡើងយានយន្ត ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេស និងតាមគំរូប្លង់ដែលបានសម្រេចរួចហើយ

-ត្រូវមានលិខិតបញ្ជាក់ពីប្រភពនៃគ្រឿងបន្លាស់យានយន្ត និងក្នុងករណីចាំបាច់ត្រូវមានការបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ចទៅលើគ្រឿងបន្លាស់ទាំងឡាយនោះ

-គ្រឿងបន្លាស់ ឬផ្នែកផ្សេងៗ ដែលត្រូវយកមកសម្រាប់កែច្នៃដំឡើងយានយន្តត្រូវមានគុណភាពល្អ អាចយកមកប្រើប្រាស់បានយ៉ាងតិច ៨០% និងត្រូវបញ្ជាក់ពីប្រភពច្បាស់លាស់ក្នុងសក្ខីប័ត្រ

-ហាមកាត់តសាក់ស៊ីរថយន្ត ឬកាត់តប្រព័ន្ធចង្កូតរថយន្ត

-រាល់ការកែច្នៃដំឡើងយានយន្ត ម្ចាស់យានដ្ឋាន ត្រូវចេញវិក័យប័ត្រជូនម្ចាស់យានយន្ត

-គ្រប់សក្ខីប័ត្រនិងវិក័យប័ត្រកែច្នៃដំឡើងយានយន្ត ម្ចាស់យានដ្ឋានត្រូវរក្សាទុកនៅទីសុវត្ថិភាពក្នុងរយៈពេល ៥ ( ប្រាំ) ឆ្នាំ ដើម្បីមានឯកសារគ្រប់គ្រាន់សម្រាប់ការត្រួតពិនិត្យដោយប្រការណាមួយ

-ក្នុងករណីមានផ្លាកលេខ ប័ណ្ណសម្គាល់ ដែលនៅសល់ពីការដោះរុះរើយានយន្ត ម្ចាស់យានដ្ឋានត្រូវប្រគល់មកឱ្យអគ្គនាយកដ្ឋានដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ដើម្បីធ្វើការជម្រះបញ្ជី ។

**ខ.៣-ការកែច្នៃដំឡើងប្រព័ន្ធម៉ាស៊ីនយានយន្ត :**

ចំពោះការកែច្នៃដំឡើងប្រព័ន្ធម៉ាស៊ីនយានយន្ត ដែលត្រូវភ្ជាប់បន្ថែមបរិក្ខាផ្សេងៗទៀត ក្នុងបំណងកាត់បន្ថយការប្រើប្រាស់ប្រេងឥន្ធនៈ ឬភ្ជាប់ប្រព័ន្ធប្រើប្រាស់ឧស្ម័ន ម្ចាស់យានដ្ឋាន ត្រូវដាក់ពាក្យសុំការអនុញ្ញាតពីអគ្គនាយកដ្ឋានដឹកជញ្ជូន តែមួយគត់ សម្រាប់ប្រព័ន្ធបច្ចេកវិទ្យាថ្មីមួយ ដោយភ្ជាប់មកជាមួយដូចខាងក្រោម :

| | |
|---|---|
| ១-ពាក្យសុំមានបិទតែមប្រៃសណីយ៍ | ១ច្បាប់ |

២-ប្រកាសស្តីពីការចុះបញ្ជីយានដ្ឋាន ថតចម្លង ១ច្បាប់

៣-លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មចាស់ ថតចម្លង ១ច្បាប់

៤-ប្លង់កែច្នៃដំឡើងប្រព័ន្ធម៉ាស៊ីនយានយន្ត ២ច្បាប់

៥-ឯកសារផ្សេងៗទៀត ដែលចាំបាច់ ។

**គ-ការផ្តល់អត្តសញ្ញាណយានយន្តកែច្នៃដំឡើង :**

ចំពោះយានយន្ត ដែលបានកែច្នៃដំឡើងរួច គ្មានលេខតួ ឬលេខកាប៊ីន ឬលេខសាក់ស៊ី ឬលេខម៉ាស៊ីន ដោយមូលហេតុណាមួយ ម្ចាស់យានដ្ឋានត្រូវដាក់ពាក្យសុំមកអគ្គនាយកដ្ឋានដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ដើម្បីកំណត់យកប្រភេទលេខ ដូចឧសម្ពន្ធ័ នៃសេចក្តីណែនាំនេះ ។

ម្ចាស់យានដ្ឋាន អាចដាប់បន្ថែមនិមិត្តសញ្ញាយានដ្ឋាន ឬក្រុមហ៊ុននៅពីខាងមុខគេបង្អស់ នៃប្រភេទលេខទាំងនោះ ។ និមិត្តសញ្ញាយានដ្ឋាន ឬក្រុមហ៊ុន ត្រូវផ្ញើមកអគ្គនាយកដ្ឋានដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ដើម្បីទទួលស្គាល់ជាផ្លូវការ ។

ហាមដាប់លេខតួ ឬលេខសាក់ស៊ី ឬលេខម៉ាស៊ីន ឬលេខកាប៊ីន ចំពោះយានយន្តដែលមានពន្ធស្រាប់ លើកលែងតែមានការអនុញ្ញាតជាមុន ពីអគ្គនាយកដ្ឋានដឹកជញ្ជូន ។ រាល់ការដាប់លេខទាំងនេះ ម្ចាស់យានដ្ឋានត្រូវស្នើសុំឱ្យមន្ត្រីពីអគ្គនាយកដ្ឋានដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ត្រួតពិនិត្យយានយន្តទាំងនោះជាមុន ដើម្បីធ្វើកំណត់ហេតុបញ្ជាក់ថា យានយន្តទាំងនោះ ពិតជាគ្មានលេខ ឬលេខទាំងនោះត្រូវលុបបាត់ដោយប្រការណាមួយ ។

ក្នុងពាក្យសុំ ម្ចាស់យានដ្ឋាន ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីមូលហេតុ ដែលនាំឱ្យបាត់លេខដើមនោះ ។

**ឃ-ការចុះបញ្ជីយានយន្តកែច្នៃដំឡើង :**

**ឃ.១-ការបង់ពន្ធយានយន្តកែច្នៃដំឡើង :**

ម្ចាស់យានយន្ត ត្រូវបំពេញកាតព្វកិច្ចពន្ធលើយានយន្តដែលបានកែច្នៃដំឡើង នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុននឹងទៅធ្វើការចុះបញ្ជីយានយន្ត ។

**ឃ.២-ការចុះបញ្ជីយានយន្តកែច្នៃដំឡើង :**

ក្រោយពីបំពេញកាតព្វកិច្ចពន្ធលើយានយន្តកែច្នៃដំឡើង រួចហើយ ម្ចាស់យានយន្ត ត្រូវដាក់ពាក្យសុំចុះបញ្ជីយានយន្តនោះ នៅអគ្គនាយកដ្ឋានដឹកជញ្ជូន ឬនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ដែលម្ចាស់យានយន្តកែច្នៃដំឡើង មានលំនៅស្ថានអចិន្ត្រៃយ៍ក្នុងរាជធានី ខេត្តនោះ ។ ដើម្បីបានដាក់ឱ្យដំណើរការ ឬធ្វើចរាចរណ៍នៅលើផ្លូវសាធារណៈ យានយន្តកែច្នៃដំឡើងនេះ ត្រូវមានសំណុំឯកសារគ្រប់គ្រាន់ ដូចជា : ផ្លាកលេខ ប័ណ្ណសម្គាល់ ប័ណ្ណបើកបរ វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណបច្ចេកទេសយានយន្ត ឬលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដឹកជញ្ជូន និងលិខិតផ្សេងៗទៀត ដែលចាំបាច់ ។

**V- អំពីការទទួលខុសត្រូវក្នុងការចាត់តាំងអនុវត្តន៍ :**

**ក-នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក :**

នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក មានតួនាទី ភារកិច្ច ណែនាំការគ្រប់គ្រង ការចុះបញ្ជី និងការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុលយានយន្ត និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ដែលមានដូចខាងក្រោម :

-ត្រូវរៀបចំក្រុមមន្ត្រីជំនាញមួយក្រុម ក្នុងការិយាល័យត្រួតពិនិត្យលក្ខណបច្ចេកទេស ដើម្បីទទួលខុសត្រូវធ្វើ

ការគ្រប់គ្រង ត្រួតពិនិត្យ តាមដាន ធ្វើរបាយការណ៍អំពីស្ថានភាពយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយាន-យន្ត នៅទូទាំងប្រទេស ជូនថ្នាក់ដឹកនាំក្រសួងសាធារណការ និងដឹកជញ្ជូន

-ក្រុមមន្ត្រីជំនាញត្រូវទទួលខុសត្រូវពិនិត្យឯកសារ ឱ្យបានគ្រប់គ្រាន់ តាមការកំណត់របស់ក្រសួង

-ត្រូវធ្វើការចុះបញ្ជី ការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ដោយត្រូវកត់ត្រាក្នុងសៀវភៅធំ និងក្នុងប្រព័ន្ធព័ត៌មានវិទ្យា ( IT ) នៅទូទាំងប្រទេស ឱ្យបានច្បាស់លាស់ ត្រឹមត្រូវ និងទាន់ពេលវេលា

-មិនត្រូវបង្កផលពិបាកដល់ការចុះបញ្ជី ការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ដល់យានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត

-ត្រូវរៀបចំតម្កល់ទុកឯកសារឱ្យមានសណ្តាប់ធ្នាប់ រៀបរយ នៅកន្លែងដែលមានសុវត្ថិភាពបំផុត ។

**ខ-មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត :**

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត មានតួនាទី ភារកិច្ច ក្នុងការគ្រប់គ្រង ការចុះបញ្ជី និងការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ដែលស្ថិតក្នុងសមត្ថកិច្ច របស់ខ្លួន មានដូចខាងក្រោម :

-ត្រូវរៀបចំក្រុមមន្ត្រីជំនាញមួយក្រុម ក្នុងការិយាល័យដឹកជញ្ជូន ដើម្បីទទួលខុសត្រូវ ធ្វើការគ្រប់គ្រងការចុះបញ្ជី ត្រួតពិនិត្យ តាមដាន ធ្វើរបាយការណ៍អំពីស្ថានភាពយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត នៅទូទាំងរាជធានី ខេត្ត របស់ខ្លួន រៀងរាល់១ឆ្នាំម្តង ជូនអគ្គនាយកដ្ឋានដឹកជញ្ជូន ដើម្បីបូកសរុប និងធ្វើរបាយការណ៍ជូនក្រសួងសាធារណការ និងដឹកជញ្ជូន

-ក្រុមមន្ត្រីជំនាញត្រូវទទួលខុសត្រូវ ពិនិត្យឯកសារ ឱ្យបានគ្រប់គ្រាន់ តាមការកំណត់របស់ក្រសួង

-ត្រូវធ្វើការចុះបញ្ជី ការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ដោយត្រូវកត់ត្រាក្នុងសៀវភៅធំ និងក្នុងប្រព័ន្ធព័ត៌មានវិទ្យា ( IT ) នៅទូទាំងរាជធានី ខេត្ត របស់ខ្លួន ឱ្យបានច្បាស់លាស់ ត្រឹមត្រូវ និងទាន់ ពេលវេលា

-មិនត្រូវបង្កផលពិបាកដល់ការចុះបញ្ជី ការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ដល់យានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត

-ត្រូវរៀបចំតម្កល់ទុកឯកសារឱ្យមានសណ្តាប់ធ្នាប់ រៀបរយ នៅកន្លែងដែលមានសុវត្ថិភាពបំផុត ។

ទទួលបានសេចក្តីណែនាំខាងលើនេះ សូមឯកឧត្តមនាយកខុទ្ទកាល័យ ឯកឧត្តមអគ្គនាយករដ្ឋបាល អគ្គនាយកសាធារណការ អគ្គនាយកដឹកជញ្ជូន លោកប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ទាំងអស់ ត្រូវចាត់ចែងអនុវត្ត តាមភារកិច្ចរៀង១ខ្លួន ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់បំផុត ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

ចម្លងជូន :
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-សាលារាជធានី ខេត្ត
"ដើម្បីជូនជ្រាប"
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ត្រាំ អ៊ីវតឹក

ឧបសម្ព័ន្ធ សេចក្តីណែនាំលេខ.............. ចុះថ្ងៃទី........ ខែ.........ឆ្នាំ២០០៩
ស្តីពីការគ្រប់គ្រងយានដ្ឋានដូសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត

*ប្រភេទលេខសម្រាប់ប្រើប្រាស់លើទោចក្រយានយន្តមាន :*

១-ប្រភេទ C50 :

ក-លេខតួ KOC-C50F-0.000.001

ខ-លេខម៉ាស៊ីន KOC-C50E-0.000.001

២-ប្រភេទ C70 :

ក-លេខតួ KOC-C70F-0.000.001

ខ-លេខម៉ាស៊ីន KOC-C70E-0.000.001

៣-ប្រភេទ C90 :

ក-លេខតួ KOC-C90F-0.000.001

ខ-លេខម៉ាស៊ីន KOC-C90E-0.000.001

៤-ប្រភេទ C100 :

ក-លេខតួ KOC-C100F-0.000.001

ខ-លេខម៉ាស៊ីន KOC-C100E-0.000.001

៥-ប្រភេទ C110 :

ក-លេខតួ KOC-C110F-0.000.001

ខ-លេខម៉ាស៊ីន KOC-C110E-0.000.001

៦-ប្រភេទ C125 :

ក-លេខតួ KOC-C125F-0.000.001

ខ-លេខម៉ាស៊ីន KOC-C125E-0.000.001

៧-ប្រភេទ CS125 :

ក-លេខតួ KOC-CS125F-0.000.001

ខ-លេខម៉ាស៊ីន KOC-CS125E-0.000.001

៨-ប្រភេទទោចក្រយានយន្ត ដែលមានកម្លាំងសេះលើសពី ១២៥សេសេ ឡើងទៅ ត្រូវកំណត់ប្រភេទលេខតួ និងលេខម៉ាស៊ីន ទៅតាមទំហំស៊ីឡាំង ដូចលំនាំខាងលើ ។

*ប្រភេទលេខសម្រាប់ប្រើប្រាស់លើគ្រឿងក្រយានយន្តខាន :*

១-ប្រភេទ C50 :

ក-លេខតួ KOC-C50F-3W-0.000.001

ខ-លេខម៉ាស៊ីន KOC-C50E-3W-0.000.001

២-ប្រភេទ C70 :

ក-លេខតួ KOC-C70F-3W-0.000.001

ខ-លេខម៉ាស៊ីន KOC-C70E-3W-0.000.001

៣-ប្រភេទ C90 :

ក-លេខតួ KOC-C90F-3W-0.000.001

ខ-លេខម៉ាស៊ីន KOC-C90E-3W-0.000.001

៤-ប្រភេទ C100 :

ក-លេខតួ KOC-C100F-3W-0.000.001

ខ-លេខម៉ាស៊ីន KOC-C100E-3W-0.000.001

៥-ប្រភេទ C110 :

ក-លេខតួ KOC-C110F-3W-0.000.001

ខ-លេខម៉ាស៊ីន KOC-C110E-3W-0.000.001

៦-ប្រភេទ C125 :

ក-លេខតួ KOC-C125F-3W-0.000.001

ខ-លេខម៉ាស៊ីន KOC-C125E-3W-0.000.001

៧-ប្រភេទ CS125 :

ក-លេខតួ KOC-CS125F-3W-0.000.001

ខ-លេខម៉ាស៊ីន KOC-CS125E-3W-0.000.001

៨- ប្រភេទគ្រឿងក្រយានយន្ត ដែលមានកម្លាំងសេះលើសពី ១២៥សេសេ ឡើងទៅ ត្រូវកំណត់ប្រភេទលេខតួ និងលេខម៉ាស៊ីន ទៅតាមទំហំស៊ីឡាំង ដូចលំនាំខាងលើ ។

*ប្រភេទលេខសម្រាប់ប្រើប្រាស់លើយានយន្តប្រភេទទេសចរណ៍មាន :*

| | |
|---|---|
| ក-លេខតួ | KOC-B1-0.000.001 |
| ខ-លេខសាក់ស៊ី | KOC-F1-0.000.001 |
| គ-លេខម៉ាស៊ីន | KOC-E1-0.000.001 |

*ប្រភេទលេខសម្រាប់ប្រើប្រាស់លើយានយន្តធុនតូច (ទម្ងន់ផ្ទុកតិចជាង ឬស្មើ ៣,៥តោន) មាន :*

| | |
|---|---|
| ក-លេខតួ | KOC-B2-0.000.001 |
| ខ-លេខសាក់ស៊ី | KOC-F2-0.000.001 |
| គ-លេខម៉ាស៊ីន | KOC-E2-0.000.001 |

*ប្រភេទលេខសម្រាប់ប្រើប្រាស់លើយានយន្តធុនធំ (ទម្ងន់ផ្ទុកលើសពី ៣,៥តោន) មាន :*

| | |
|---|---|
| ក-លេខតួ | KOC-B3-0.000.001 |
| ខ-លេខសាក់ស៊ី | KOC-F3-0.000.001 |
| គ-លេខម៉ាស៊ីន | KOC-E3-0.000.001 |

*ពាក្យសម្រាយអក្សរកាត់ ដែលប្រើប្រាស់ខាងលើនេះ មានន័យដូចខាងក្រោម :*

| | | |
|---|---|---|
| - KOC | មានន័យជាភាសាអង់គ្លេសថា | Kingdom of Cambodia |
| - B | មានន័យជាភាសាអង់គ្លេសថា | Body |
| - E | មានន័យជាភាសាអង់គ្លេសថា | Engine |
| - F | មានន័យជាភាសាអង់គ្លេសថា | Frame |
| - W | មានន័យជាភាសាអង់គ្លេសថា | Wheel |